PeaceHealth

# សិទ្ធិនិងការទទួលខុសត្រូវរបស់អ្នកជម្ងឺ

**PATIENT RIGHTS AND RESPONSIBILITIES**

This document is also available in Spanish, Vietnamese, Cambodian, and Russian. Please ask at the desk for any of these versions.

Este docuemnto está disponible en Español, Vietnamita,Cambodiano, e Ruso. Por favor pregunte en el escritorio por cualquiera de estas versiones.

**Tài liệu cũng có sẵn bằng tiếng Tây Ban Nha, Nga, Cam Bốt, và bằng tiếng Việt-nam. Hãy yêu cầu các bản này tại bàn tiếp tân.**

*ឯកសារនេះត្រូវបានប្រែសម្រួលជូនជាភាសា អេស្ប៉ាញ៉ុល, វៀតណាម, ខ្មែរ, និង រូស្ស៊ី ។ សូមសាកសួរបុគ្គលិកទទួលភ្ញៀវ សម្រាប់ភាសាណាមួយ ។*

***Вы также можете запросить этот документ на русском, испанском, вьетнамском и камбоджийском языках.***

**សូមស្វាគមន៍**

ក្នុងនាមជាអ្នកជម្ងឺម្នាក់របស់មណ្ឌលវេជ្ជសាស្ត្រ សិន្តចន (St. John Medical Center) ឬក្រុមវេជ្ជសាស្ត្រសន្តិភាពសុខភាព (PeaceHealth Medical Group), លោកអ្នកមានសិទ្ធិនិងការទទួលខុសត្រូវមួយចំនួន ។ លោកអ្នកក៏មានសិទ្ធិផ្តល់អនុសាសអំពីសេចក្តីបារម្ភនានា ដែលលោកអ្នកឬក្រុមគ្រួសារ របស់លោកអ្នកអាចមានចំពោះការថែទាំព្យាបាលរបស់លោកអ្នក ឬអំពីបុគ្គលិកលក្ខណៈនៃសេវាកម្មដែលលោកអ្នកបានទទួលកន្លងទៅហើយនោះដែរ ។ សិទ្ធិនិងការទទួលខុសត្រូវរបស់លោកអ្នក និងលក្ខណៈផ្តល់ពត៌មានដល់យើងខ្ញុំស្តីពីសេចក្តីបារម្ភរបស់លោកអ្នក ត្រូវបានផ្តលជូនជាគោលសង្ខេបៗដូចខាង ក្រោមនេះ ៖

**ក្នុងនាមជាអ្នកជម្ងឺម្នាក់, លោកអ្នកមានសិទ្ធិដើម្បី ៖**

1. ថែទាំព្យាបាលដោយគោរពនិងយកចិត្តទុកដាក់; រួមមានទាំងការគោរពកោតសរសើរចំពោះតម្លៃនិងលទ្ធិជំនឿឯកត្តបុគ្គលផ្ទាល់របស់លោកអ្នក ។
2. មានលទ្ធភាពទទួលសេចក្តីទំនុកបម្រុងផ្នែកជំនឿសាសនា និងសេវាកម្មផ្នែកព្រលឹកវិញ្ញាណផ្សេងៗទៀត ។
3. មានសិទ្ធិប្រទានការណែនាំរបៀបព្យាបាលជាមុន និង/ឬតែងតាំងអ្នកជំនួសណាម្នាក់ដើម្បីសម្រេចនូវរាល់ជម្រើសនៃការថែទាំសុខ ភាព ដូចដែលបានអនុញ្ញាតឲ្យដោយច្បាប់ និងដើម្បីឲ្យបុគ្គលិកនិងអ្នកជំនាញការរបស់មន្ទីរពេទ្យ ដែលផ្តល់សេវាថែទាំនានាក្នុង មន្ទីរពេទ្យគោរពប្រតិបត្តិតាមសិទ្ធិប្រទានការណែនាំទាំងឡាយនោះ; រួមមានទាំងការរក្សាទុកនិងដកហូតនូវអស់សេវាសង្គ្រោះជីវិត និង/ឬវិធីព្យាបាលសំរាប់ទ្រទ្រង់ជីវិតនានា ។ លក្ខខ័ណ្ឌនៃការថែទាំព្យាបាលមិនអាស្រ័យលើវត្តមានសិទ្ធិប្រទានការណែនាំរបៀប ព្យាបាលជាមុនទេ ។ ពត៌មានអំពីសិទ្ធិប្រទានការណែនាំរបៀបព្យាបាលជាមុន និងការធ្វើវិភាគទានសរីរាង្គអាចត្រូវបានផ្តលជូន លោកអ្នក ទៅតាមសេចក្តីស្នើសុំ ។
4. មានលទ្ធភាពទទួលពត៌មានដែលមានក្នុងបញ្ជីឯកសារវេជ្ជសាស្ត្ររបស់លោកអ្នក ដោយអនុលោមទៅតាមបទបញ្ជារបស់រដ្ឋនិងសហព័ន្ធ ហើយ និងគោលការរបស់មន្ទីរពេទ្យ ។
5. ទទួលពីវេជ្ជបណ្ឌិតរបស់លោកអ្នកនូវពត៌មានស្តីពីការថែទាំព្យាបាលនិងស្ថានភាពសុខភាពរបសលោកអ្នក ក្នុងភាសាសព្ទដែលលោកអ្នកអាច ងាយយល់បាន ។ ករណីវនេះអាចប្រព្រឹត្តទៅក្នុងរបៀបជាធម្មតាក៏បាន ឬក្នុងរបៀបជាសន្និសិទគ្រួសារ/អ្នកជម្ងឺ ជាមួយសមាជិកនៃក្រុមអ្នក ថែទាំសុខភាពរបស់លោកអ្នកក៏បាន ។ លោកអ្នកអាចសុំឲ្យរាប់បញ្ចូលឬដកចេញនូវសមាជិកគ្រួសារណាម្នាក់ពីការស្តាប់ពត៌មាននេះបាន ។
6. ចូលរួមចំណែកក្នុងការដោះស្រាយបញ្ហាច្រកដើរនៃដំណើរគ្រោះចំពោះការសម្រេចចិត្តរើសយកការថែទាំព្យាបាលណាមួយ ។
7. ចូលរួមចំណែកក្នុងការពិនិត្យពិចារណាលើបញ្ហាក្រមសីលធម៌ ដែលកើតមានឡើងក្នុងពេលថែទាំព្យាបាលរបស់លោកអ្នក ។
8. ទទួលពត៌មានទាំងឡាយណាដែលចាំបាច់សំរាប់យកមករិះគិតពិចារណា ដើម្បីប្រគល់សេចក្តីយល់ព្រម<u>មុននឹង</u>ចាប់ផ្តើមបើកប្រតិបត្តិការលើដំណើរ ការណាមួយ ។ លើកលែងតែនៅក្នុងករណីមានភាពអាសន្ន, ជាធម្មតា ពត៌មាននេះមានរួមបញ្ចូលទាំងបទពិពណ៌នារៀបរាប់នូវទ្រង់ទ្រាយនៃ ដំណើរការ, ផលប្រយោជន៍សំខាន់ៗនិងគ្រោះថ្នាក់ពាក់ព័ន្ធ, ថេរវេលាដែលលោកអ្នកអាចនឹងប្រកបកិច្ចការអ្វីមួយពុំបាន, និងការប្រើប្រាស់ ថ្នាំព្យាបាលផ្លាស់ប្តូរគ្នាទៅតាមហេតុផលតម្រូវ ។
9. ការយល់ព្រម(សេចក្តីអនុញ្ញាត)ត្រូវបានគេប្រើប្រាស់ស្របច្បាប់សំរាប់ថតជាសម្លេងឬជាខ្សែភាពយន្ត ផលិតឡើងសម្រាប់ប្រើប្រាស់ក្នុងគោល បំណងផ្សេងៗជាច្រើនទៀត ក្រៅពីការពិនិត្យសិក្សាភិនភាគ, រោគវិនិច្ឆ័យ, ឬវិធីការព្យាបាលអ្នកជម្ងឺ ។
10. ស្គាល់ឈ្មោះវេជ្ជបណ្ឌិតទាំងប៉ុន្មានដែលកំពុងព្យាបាលលោកអ្នក ហើយថា តើវេជ្ជបណ្ឌិតណាម្នាក់កំពុងសម្របសម្រួលការព្យាបាលរបស់លោក អ្នក ។
11. ច្រានចោលការព្យាបាល និងទទួលបានការថ្លែងពន្យល់ពីផលវិបត្តិផ្នែកវេជ្ជសាស្ត្រ ដែលបង្កឡើងពីការច្រានចោលរបស់លោកអ្នក ។
12. រួមចំណែកក្នុងការសម្រេចរើសរកការថែទាំដ៏ជាទីពំនាក់នាគ្រាចុងបញ្ចប់នៃជីវិត ។
13. ទទួលបាននូវការថ្លែងពន្យល់ ឬកាលបើដល់ពេលសមរម្យណាមួយហើយ សុំឲ្យក្រុមគ្រួសារបានពន្យល់ប្រាប់អំពីលទ្ធផលនៃការថែទាំ ដោយរាប់ ទាំងលទ្ធផលដែលអាចស្មានមិនដល់ផង ។
14. ឲ្យមានសេរីភាពពីការដាក់លក្ខខ័ណ្ឌកម្រិតក្នុងការទាក់ទង លើកលែងតែក្នុងករណីមានការប្រមាណមើលសំរាប់ប្រសិទ្ធិភាពព្យាបាលរោគ ។
15. ទទួលសេវាកម្មផ្នែកប្រែសម្រួលភាសាសំរាប់អ្នកជម្ងឺដែលខ្វះជំនាញភាសាអង់គ្លេស ឬមានការពិបាកក្នុងការស្តាប់ ។
16. ស្វែងរកដំណោះស្រាយចំពោះបណ្តឹងតវ៉ាដោយគ្មានការបង្ខិតបង្ខំ, ការរើសអើង, ការផ្តាញ់ផ្តាល់, ឬការកាត់ផ្តាច់ពីការថែទាំដោយឥតសមហេតុ សមផល, ការព្យាបាល, និងសេវាបម្រើនានា ។
17. សិទ្ធិឯកជនក្នុងកិច្ចការថែទាំព្យាបាលជម្ងឺរបស់លោកអ្នក ។
18. ភាពរក្សាការសម្ងាត់នូវបញ្ជីឯកសារនិងការនិយាយទាក់ទងក្នុងដំណើរការថែទាំព្យាបាលរបស់លោកអ្នក ។ ពត៌មានខ្លះអាចត្រូវគេបញ្ចេញទៅឲ្យ មនុស្សឬទីភ្នាក់ងារដែលជាប់ពាក់ព័ន្ធមួយចំនួន (ឧទាហរណ៍ដូចជា ៖ ក្រុមហ៊ុនធានារ៉ាប់រងជាដើម) ដោយអនុលោកទៅតាមច្បាប់រដ្ឋ និង/ឬ ច្បាប់របស់សហព័ន្ធ ។
19. ទទួលការថែទាំព្យាបាលក្នុងបរិយាកាសមួយដ៏មានសុវត្ថិភាព, រក្សាបាននូវសេចក្តីថ្លៃថ្នូរ, និងជួយឲ្យបាននូវនិមិត្តរូបជាវិជ្ជមានមួយសំរាប់ខ្លួន ។
20. មានសេរីភាពពីការរំលោភបំពានឬការញាំញីរំខានគ្រប់ទ្រង់ទ្រាយ ។

## *សិទ្ធិនិងការទទួលខុសត្រូវរបស់អ្នកជម្ងឺ (បន្ត)*

21. ក្នុងនាមជាអ្នកជម្ងឺម្នាក់នៅមន្ទីរពេទ្យនេះ, លោកអ្នកអាចទទួលបាន៖ ពត៌មានអំពីការឈឺចាប់និងបរិមាណបន្ធូរបន្ថយការឈឺចាប់, បុគ្គលិកដែលស្គាល់ទុក្ខធុរៈបានផ្ដាក់ញារការពារនិងចាត់ចែងសម្រួលការឈឺចាប់ដោយយកចិត្តទុកដាក់ជាទីបំផុត, អ្នកឯកទេសផ្នែកសុខភាពដែលឆ្លើយតបរហ័សទាន់ចិត្តទៅនឹងរបាយការណ៍នៃការឈឺចាប់, អ្នកឯកទេសផ្នែកសុខភាពដែលជឿទុកចិត្តនឹងសេចក្ដីរាយការណ៍ពីការឈឺចាប់, ការរក្សា ឃ្លាំមើលការឈឺចាប់របស់លោកអ្នក, ឧបករហ៍សម្រួលការឈឺចាប់ដ៏ទំនើបទាន់សម័យ ។
22. លទ្ធភាពទទួលសេវាកម្មឧបត្ថម្ភការពារដែលបានរៀបសម្រួលដោយអង្គការនេះ ។
23. ផ្ដល់ឲ្យឬរក្សាទុកនូវសេចក្ដីយល់ព្រមរបស់លោកអ្នកចំពោះការចូលរួមក្នុងកម្មវិធីឬកិច្ចការស្រាវជ្រាវនានា ។ ករណីនេះគឺរាប់បញ្ចូលទាំងពត៌ មានអំពីកម្មវិធី, ការប្រថុយគ្រោះថ្នាក់និងការពុំមានអារម្មណ៍កក់ក្ដៅក្នុងចិត្ត, និងផលប្រយោជន៍នៃការចូលរួមក្នុងកម្មវិធីនោះ ។
24. លទ្ធភាពឥតលំអៀងក្នុងការទទួលបាននូវសេវាកម្មវេជ្ជសាស្ត្រដូចដែលបានណែនាំបង្ហាញជូនទាំងប៉ុន្មាន ដែលមាននៅនឹង PeaceHealth ។
25. រួមសកម្មក្នុងការរៀបចំផែនការណ៍ថែទាំនិងវិធីព្យាបាល ។
26. ទទួលការផ្ដល់ពត៌មានពន្យល់ពីស្ថានភាពសុខភាពរបស់លោកអ្នក ។
27. ស្នើសុំសិទ្ធិជ្រើសរើសយកវិធីព្យាបាលដ៏សមហេតុផលណាមួយ ដែលគេចាត់ទុកថាជាខ្នាតមូលដ្ឋាននៃការថែទាំព្យាបាល ។
28. ពិគ្រោះយោបល់ជាមួយវេជ្ជបណ្ឌិតណាម្នាក់ទៅតាមការស្នើសុំនិងចំណាយធនរបស់លោកអ្នក ។
29. ឲ្យសមាជិកគ្រួសារឬអ្នកតំណាងនិងគ្រូពេទ្យ (ប្រចាំគ្រួសារ) របស់លោកអ្នក ផ្ដល់ដំណឹងជាលាយលក្ខណ៍អក្សររហ័សទាន់ពេល ក្នុងករណីដែល លោកអ្នកត្រូវបានទទួលចុះឈ្មោះឲ្យស្នាក់អាស្រ័យនៅមន្ទីរពេទ្យ ។
30. មានសេរីភាពពីការស្នាក់នៅដាច់ពីគេ និង/ឬ ការដាក់កំរិតក្នុងទ្រង់ទ្រាយណាមួយដែលមិនចាំបាច់ចំពោះវិធីព្យាបាល ឬត្រូវគេប្រើប្រាស់ក្នុង ន័យបង្ខិតបង្ខំ, ដាក់វិន័យ, ស្រណុកស្រួល, ឬសងសឹកពីសំណាក់បុគ្គលិកធ្វើការ ។
31. ទទួលការថែទាំព្យាបាលតាមខ្នាតជាមូលដ្ឋានដូចគេឯង ដោយមិនគិតអំពីសមត្ថភាពបង់ប្រាក់ និងឱកាសដើម្បីពិនិត្យមើលនិងទទួលបាននូវ សេចក្ដីពន្យល់ដែលមានចែងលើសំបុត្រទារប្រាក់របស់មន្ទីរពេទ្យឬវេជ្ជបណ្ឌិត ។

**ក្នុងនាមជាអ្នកជម្ងឺម្នាក់, លោកអ្នកមានការទទួលខុសត្រូវចំពោះ៖**

1. ការចូលរួមយ៉ាងសកម្មក្នុងការធ្វើការសម្រេចចិតចំពោះការថែទាំសុខភាពរបស់លោកអ្នក ។
2. ការផ្ដល់ពត៌មានដែលទាក់ទងប្រវត្តវេជ្ជសាស្ត្ររបស់លោកអ្នកដោយត្រឹមត្រូវ, ពេញលេញ, និងទាន់ពេលវេលា៖ ប្រវត្តទាំងនោះមានដូចជា រោគសញ្ញានិងបញ្ហានានា, និងរឿងរ៉ាវផ្សេងៗដែលជាប់ពាក់ព័ន្ធនឹងសុខភាពរបស់លោកអ្នក ។
3. ក្នុងនាមជាអ្នកជម្ងឺម្នាក់នៅមន្ទីរពេទ្យនេះ, យើងសង្ឃឹមថា លោកអ្នកនឹងសាកសួរវេជ្ជបណ្ឌិតឬគិលានុបដ្ឋាយការរបស់លោកអ្នក ពីអ្វីដែលគួរគិតស្មានទុកជាមុនចំពោះការឈឺចាប់និងការជួយសម្រួលដល់ការឈឺចាប់នោះ, សូមពិគ្រោះពិភាក្សាអំពីជម្រើសនៃការជួយបន្ធូរការឈឺចាប់ជាមួយ វេជ្ជបណ្ឌិតនិងគិលានុបដ្ឋាយការរបស់លោកអ្នក, សូមធ្វើការជាមួយវេជ្ជបណ្ឌិតនិងគិលានុបដ្ឋាយការរបស់លោកអ្នក ដើម្បីគ្រោងផែនការណ៍ជួយ សម្រួលការឈឺចាប់មួយឡើង, សូមសាកសុំថ្នាំបំបាត់ការឈឺចាប់ នៅពេលណាការឈឺចាប់ផ្ដើមកម្រើកឡើង, សូមជួយអ្នកផ្ដល់សេវាបម្រើនិង គិលានុបដ្ឋាយការរបស់លោកអ្នក ឲ្យប្រមាណមើលការឈឺចាប់របស់លោកអ្នក, សូមប្រាប់ដល់អ្នកផ្ដល់សេវាបម្រើឬគិលានុបដ្ឋាយការរបស់លោក អ្នក បើការឈឺចាប់របស់លោកអ្នកមិនព្រមធូរស្បើយទេ, ហើយសូមប្រាប់អ្នកផ្ដល់សេវាបម្រើឬគិលានុបដ្ឋាយការរបស់លោកអ្នកអំពីកង្វល់នានា ដែលលោកអ្នកមានចំពោះការទទួលទានថ្នាំបំបាត់ការឈឺចាប់ ។
4. ការសាកសួរសំណួរនិងស្វែងរកការជួយបំភ្លឺច្បាស់លាស់ ដើម្បីឲ្យបានយល់ និងដើម្បីឲ្យគេមានឱកាសជំរាបពត៌មានអំពីរោគវិនិច្ឆ័យនិងវិធីព្យា បាលរបស់លោកអ្នក ហើយក៏ត្រូវសាកសួរឲ្យដឹងដែរថា តើគេរំពឹងចង់បានអ្វីពីលោកអ្នកវិញនោះ ។
5. ការជូនដំណឹងជាលាយលក្ខណ៍អក្សរដល់វេជ្ជបណ្ឌិតឬគិលានុបដ្ឋាយការរបស់លោកអ្នកជាបន្ទាន់ ប្រសិនបើ៖
    - លោកអ្នកបានសំគាល់ឃើញថាមានការផ្លាស់ប្តូរណាមួយកើតឡើងចំពោះសុខភាពរបស់លោកអ្នក ។
    - លោកអ្នកមានការព្រួយបារម្ភណាមួយចំពោះសុខភាពរបស់លោកអ្នក ។
    - លោកអ្នកមិនអាចឬនឹងមិនធ្វើតាមផែនការណ៍ព្យាបាលជម្ងឺភាគខ្លះ ។
6. ការធ្វើតាមសេចក្ដីណែនាំនិងឱវាទរបស់វេជ្ជបណ្ឌិតរបស់លោកអ្នក ។
7. ការគិតថ្លឹងថ្លែងពិចារណាចំពោះអ្នកជម្ងឺដទៃនិងបុគ្គលិកមន្ទីរពេទ្យ ហើយសូមជួយគ្រប់គ្រងសម្លេងអ៊ូអែ, ផ្សែង, និងចំនួនអ្នកមកសួរសុខទុក្ខ ។
8. ការចេះគោរពដល់សម្បត្តិកម្មសិទ្ធិរបស់អ្នកដទៃនិងរបស់មន្ទីរពេទ្យ, ហើយត្រូវធ្វើតាមច្បាប់វិន័យនានារបស់មន្ទីរពេទ្យ ដែលកំពុងមានសុពល ភាពលើការថែទាំព្យាបាលនិងក្រមសីលធម៌របស់អ្នកជម្ងឺ ។
9. ការធានាថា កាតព្វកិច្ចផ្នែកប្រាក់កាសដែលត្រូវបង់លើសេវាថែទាំសុខភាពរបស់លោកអ្នក ត្រូវបំពេញឲ្យបានទៀងទាត់ទាន់ពេលវេលា ។
10. **របៀបផ្ដល់អនុសាសចំពោះការបារម្ភ**៖ ប្រសិនបើលោកអ្នកមានសេចក្ដីបារម្ភ, សំណួរ, ឬចង់ផ្ដល់នូវសេចក្ដីសរសើរណាមួយ, សូម៖
    - ទាក់ទងជាមួយនាយកគ្រប់គ្រងនៃក្រសួងដែលជាប់ពាក់ព័ន្ធ ។

      \- ឬ -
    - ទូរស័ព្ទទាក់ទងតាមបណ្ដាញអនុសាសនៃសេចក្ដីបារម្ភរបស់មន្ទីរពេទ្យ៖
        - ពីក្នុងមន្ទីរពេទ្យ, សូមទូរស័ព្ទតាមលេខបន្ត (Extension ឬ Ext.) 4894 ។
        - ពីក្រៅមន្ទីរពេទ្យ, សូមទូរស័ព្ទតាមលេខ 636-4894, ឬលេខឥតបង់ប្រាក់, 1-800-438-7562, Ext. 4894 ។

      \- ឬ -
    - ដោយសរសេរទៅ៖

      Renee Neville<br>
      Center for Healthcare Improvement<br>
      PeaceHealth<br>
      P.O. Box 3002<br>
      Longview, WA 98632-0302
    - ដោយសរសេរទៅ ឬ ទូរស័ព្ទទាក់ទងជាមួយ៖

      Office of Quality Monitoring<br>
      JCAHO Commission on Accreditation of Healthcare Organizations<br>
      One Renaissance Blvd.<br>
      Oakbrook Terrace, IL 60181<br>
      តាមលេខ (800) 994-6610 (ម៉ោង 8:30 ព្រឹកដល់ម៉ោង 5:00 ល្ងាច, តាមពេលម៉ោង Central Standard Time, M-F)
    - លោកអ្នកអាចទាក់ទងទៅក្រសួង Washington State Department of Health តាមលេង 1-800-633-6828 ។